# រឿង ដៃ ជើង មាត់ប្រណែននឹងក្រពះ



# រឿង ដៃ ជើង មាត់ច្រណែននឹងក្រពះ

រៀបរៀងដោយ វ៉ីន សុន

គូររូបដោយ លោក គាំ សារ៉ែន

រក្សាសិទ្ធិដោយ អង្គការសន្តិស្មុំគ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០១៣

# រឿង ដៃ ជើង មាត់ប្រណែននឹងក្រពះ



ថ្ងៃមួយ ដៃ ជើង និងមាត់ជជែកគ្នា ។





ពេលនោះ ជើងនិយាយមុនគេថា
"សព្វថ្ងៃនេះ យើងនឿយហត់ណាស់" ។





ដៃឆ្លើយថា "មែនហើយ!  ចំណែកខ្ញុំវិញ រឹតតែរវល់គ្មានពេលទំនេរសោះ" ។





មាត់ឆ្លើយតបភ្លាម : "ហ៊ឺ! ខ្ញុំរវល់ខ្លាំងជាងពួកអ្នកទៅទៀត ។ ខ្ញុំនិយាយផង! ខ្ញុំទំពាផង! រួចខ្ញុំត្រូវលេបបញ្ជូនទៅទៀត!" ។

ដៃជើងសួរទៅមាត់ភ្លាម :

"តើអាហារអ្នកបញ្ជូនទាំងនោះ ធ្លាក់ទៅលើអ្នកណា?" ។

មាត់ឆ្លើយ : "អូ! គ្មាននរណាក្រៅពីក្រពះទេ!" ។





មាត់ឆ្លើយថាៈ

“អូ! គ្មាននរណាក្រៅពីក្រពះទេ!” ។

ជើងស្រែកថា "ខ្ញុំដើរគ្រប់ទីកន្លែងដើម្បីរកអាហារហត់
ខ្លាំងណាស់ តែមិនបានទទួលផលអ្វីសោះ" ។







ដៃពោលបន្ថែម "ចំណែកខ្ញុំវិញ
សូម្បីតែពេលដេកក៏ខ្ញុំធ្វើការដែរ" ។



ជជែកគ្នារួច ពួកគេក៏និយាយព្រមៗគ្នាថា

"ពួកយើងមិនសុខចិត្តទេ ត្រូវតែឈប់ធ្វើការដើម្បីបង្អត់អាហារឱ្យក្រពះស្វិតតែម្តងទៅ" ។

ក្រោយពេល ក្រពះគ្មានអាហារកិនបញ្ជូនទៅ រាងកាយទាំងមូលក៏ចុះខ្សោយ ។





ដោយមានបញ្ហាខុសប្រក្រតី ដៃ ជើង មាត់ បានពិភាក្សាគ្នា សាចុះសាឡើង តែរកមូលហេតុមិនឃើញសោះ ។





ពេលនោះ ក្រពះនិយាយ "ពួកអ្នកមើលឃើញតែអ្វីៗដែលនៅជុំវិញខ្លួន ពិសេសគិតតែខ្លួនឯង ។ ខ្លួនខ្ញុំជាក្រពះខិតខំបញ្ជូនអាហារសម្រាប់អ្នកទាំងអស់គ្នា" ។









មួយរំពេចនោះ ជើងយល់សេចក្ដីច្បាស់មុនគេ វាប្រឹងស្ទុះ
សំដៅទៅតុអាហារ ។

ឯដៃប្រញាប់ចាប់ចំណីបញ្ចុកមាត់ ។

មាត់ក៏ទំពា គ្រូបៗយ៉ាងឆ្ងាញ់! ។

គ្រានោះ ក្រពះញញឹមទទួលអាហារ ព្រមទាំងនិយាយថា:
"អរគុណ! អ្នកទាំងអស់គ្នា" ។





ទីបំផុត រាងកាយក៏បានរឹងមាំឡើងវិញ ហើយស្រែកច្រៀងថា៖
"ឡាឡាឡា សាមគ្គីនាំមកនូវសេចក្ដីសុខ" ៕

ចប់





*Move forward, hand in hand.*

Shanti Volunteer Association

*Stand with people in need around the world.*